**នៅចំពោះមុខ អង្គបុរេជំនុំជម្រះ**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

| | |
|---|---|
| សំណុំរឿងលេខ៖ | ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស |
| ភាគីដាក់ឯកសារ៖ | សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី |
| ដាក់ជូន៖ | អង្គជំនុំជម្រះតុលាការកំពូល |
| ភាសាដើម៖ | អង់គ្លេស |
| កាលបរិច្ឆេទឯកសារ៖ | ថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៩ |

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 07-Oct-2019,15:35
CMS/CFO: Sann Rada

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ៖ **សាធារណៈ/Public**

ស្ថានភាពនៃចំណាត់ថ្នាក់ឯកសារ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

**សារណារបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាក់ទិននឹងចម្លើយតប របស់ ខៀវ សំផន ទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា**

---

<u>ដាក់ដោយ</u>៖

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ពេជ្រ អង្គ

Megan HIRST

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ជេត វណ្ណលី

ហុង គីមសួន

ឡោ ជុនធី

ម៉ុច សុវណ្ណារី

<u>ដាក់ជូន</u>៖

**ចៅក្រម គង់ ស្រីម ប្រធាន**

**ចៅក្រម Chandra Nihal JAYASINGHE**

**ចៅក្រម សោម សិរីវឌ្ឍ**

**ចៅក្រម Florence Ndepele MWACHANDE-MUMBA**

**ចៅក្រម ម៉ុង មុនីចរិយា**

**ចៅក្រម Maureen Harding CLARK**

**ចៅក្រម យ៉ា ណារិន**

Original EN: 01628272-01628278

សុិន សុវ៉ន

សំ សុគង់

វ៉ែន ពៅ

ទី ស្រីណា

Olivier BAHOUGNE
Laure DESFORGES
Ferdinand DJAMMEN NZEPA
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Yiqiang LIU
Daniel LOSQ
Christine MARTINEAU
Lyma NGUYEN
Nushin SARKARATI
Mahesh RAI

<u>ផ្ញើជូន</u>៖

**សហព្រះរាជអាជ្ញា**

ជា លាង

Brenda J. HOLLIS

**ជនជាប់ចោទ៖**

ខៀវ សំផន

**សហមេធាវីការពារក្តីជនជាប់ចោទ៖**

លោក គង់ សំអុន

Anta GUISSÉ

## I. សេចក្តីផ្តើម

១. នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសង្ខេបនៃសាលក្រមរបស់ខ្លួននៅក្នុងសំណុំរឿង ០០២/០២ ក្នុងអំឡុងសវនាការជាសាធារណៈ[១]។ នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩ សាលក្រមដែលមានសំអាងហេតុពេញលេញត្រូវបានជូនដំណឹងដល់ភាគីជាភាសាខ្មែរ អង់គ្លេស និងបារាំង[២]។ ក្រោយពីមានសំណើពី ខៀវ សំផន និង នួន ជា អង្គជំនុំជម្រះតុលាការកំពូលបានបង្គាប់ឱ្យភាគីដាក់សេចក្តីជូនដំណឹងទាំងអស់ឱ្យបានមុនថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩[៣]។ ការិយាល័យសហព្រះរាជអាជ្ញា និងមេធាវីការពារក្តីទាំងពីរក្រុមបានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ជំទាស់ទៅនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង[៤]។ នួន ជា បានទទួលមរណភាពនៅថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៩ ហើយកិច្ចដំណើរការនីតិវិធីចំពោះរូបគាត់ត្រូវបានបញ្ចប់[៥]។

២. សហព្រះរាជអាជ្ញាបានដាក់សារណាបណ្តឹងសាទុក្ខរបស់ខ្លួននៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៩ ដោយកំណត់ទទ្បីករណ៍មួយជាមូលហេតុនៃបណ្តឹងសាទុក្ខដែលពាក់ព័ន្ធនឹងជនរង

---

[១] *សូមមើល* ឯកសារ **E1/529.1** ប្រតិចារឹកនៃសវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨។

[២] ឯកសារ **E465** សាលក្រមក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ (សាលក្រមដែលមានសំអាងហេតុពេញលេញត្រូវបានជូនដំណឹងនៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩)។

[៣] ឯកសារ **F43** សេចក្តីសម្រេចលើសំណើរបស់ នួន ជា និង ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩ កថាខណ្ឌ ១៣។

[៤] ឯកសារ **E465/2/1** សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញា អំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ (ដោយកំណត់ទទ្បីករណ៍តែមួយជាមូលដ្ឋាននៃបណ្តឹងសាទុក្ខ)។ ឯកសារ **E465/4/1** សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់លោក ខៀវ សំផន (សំណុំរឿង ០០២/០២) ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ (ដោយបង្ហាញនូវកំហុសចំនួន ១.៨២៤ និងសេចក្តីសម្រេចចំនួន ៣៥៥ របស់អង្គជំនុំជម្រះសាលាដំបូង)។ ឯកសារ **E465/3/1** សេចក្តីជូនដំណឹងរបស់ នួន ជា អំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០២ (ដោយកំណត់នូវមូលដ្ឋានចំនួន ៣៥១ នៃបណ្តឹងសាទុក្ខ)។

[៥] ឯកសារ **F46/3** សេចក្តីសម្រេចបញ្ចប់កិច្ចដំណើរការនីតិវិធីលើជនជាប់ចោទ នួន ជា ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៩។

គ្រោះជាបុរសនៃការរួមភេទដោយបង្ខំ[៦]។ នៅក្នុងបណ្តឹងសាទុក្ខរបស់ខ្លួន សហព្រះរាជអាជ្ញាសំអាងមួយផ្នែកទៅលើភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី អែម អឿន[៧] មុំ វុន[៨] ស៊្វ សុធារី[៩] និង យស់ ផល[១០]។ ក្រោយពេលទទួលបានពេលវេលាបន្ថែម[១១] ខៀវ សំផន បានដាក់សារណាតបរបស់ខ្លួនទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញានៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៩[១២]។ សារណាតបនេះត្រូវបានជូនដំណឹងនៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ ២០១៩។ សារណាតបរបស់ ខៀវ សំផន សំអាងមួយផ្នែកទៅលើភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី សេង សឿន[១៣] កុល ណែម[១៤] មាន លឿយ[១៥] ម៉ី សារឿន[១៦] ប្រាក់ ឌឿន[១៧] សយ ណារឿន[១៨] អ៊ុំ យឿន[១៩] ប៉ែន សុចាន់[២០] ជុំ សាមឿន[២១] ជា ឌៀប[២២] ព្រាប

[៦] ឯកសារ **F50** បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៩ ("សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា")។

[៧] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៩។

[៨] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៦-៣៧។

[៩] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៧។

[១០] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៧។

[១១] ឯកសារ **F49** សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់ដាក់សារណាបណ្តឹងសាទុក្ខ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ កថាខណ្ឌ ៣៦។

[១២] ឯកសារ **F50/1** ចម្លើយតបរបស់មេធាវីការពារក្តីលោក ខៀវ សំផន ទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា (សំណុំរឿង ០០២/០២) ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៩ ("សារណាតបរបស់ ខៀវ សំផន")។

[១៣] សារណាតបរបស់ ខៀវ សំផន កថាខណ្ឌ ៤៧។

[១៤] សារណាតបរបស់ ខៀវ សំផន កថាខណ្ឌ ៤៨។

[១៥] សារណាតបរបស់ ខៀវ សំផន កថាខណ្ឌ ៥១។

[១៦] សារណាតបរបស់ ខៀវ សំផន កថាខណ្ឌ ៥២។

[១៧] សារណាតបរបស់ ខៀវ សំផន កថាខណ្ឌ ៦៩។

[១៨] សារណាតបរបស់ ខៀវ សំផន កថាខណ្ឌ ៧០។

[១៩] សារណាតបរបស់ ខៀវ សំផន កថាខណ្ឌ ៧១។

[២០] សារណាតបរបស់ ខៀវ សំផន កថាខណ្ឌ ៧៣។

[២១] សារណាតបរបស់ ខៀវ សំផន កថាខណ្ឌ ៧៤។

[២២] សារណាតបរបស់ ខៀវ សំផន កថាខណ្ឌ ៧៥។

សុឃឿន[២៣] និង សុន វុត[២៤] ព្រមទាំងបានជំទាស់ទៅនឹងទឡ្ហីករណ៍នានាពាក់ព័ន្ធនឹងដើមបណ្ដឹងរដ្ឋប្បវេណីចំនួនបួនរូបដែលសហព្រះរាជអាជ្ញាបានយកមកពិភាក្សា[២៥]។

៣. ដោយយល់ដឹងពីដែនកំណត់នៃសិទ្ធិចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដូចដែលអង្គជំនុំជម្រះតុលាការកំពូលបានពន្យល់ពីមុនរួចមកហើយនោះ[២៦] សហមេធាវីនាំមុខគ្មានបំណងធ្វើការឆ្លើយតបទៅនឹងបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញានោះឡើយ។ ទោះជាយ៉ាងណាក្ដី សហមេធាវីនាំមុខត្រូវបង្ខំចិត្តដាក់សារណាដែលបានកម្រិតទាំងនេះ ពាក់ព័ន្ធនឹងសិទ្ធិ និងផលប្រយោជន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី ដែលទទួលរងប៉ះពាល់ពីសារណាតបរបស់ ខៀវ សំផន។

## II. ច្បាប់ជាធរមាន

៤. វិធាន ២១(១)(គ) នៃវិធានផ្ទៃក្នុងចែងថា "អ.វ.ត.ក ត្រូវធានាថា ជនរងគ្រោះត្រូវទទួលបានការជូនព័ត៌មាន ហើយសិទ្ធិរបស់ជនរងគ្រោះ ត្រូវបានការពារក្នុងអំឡុងពេលនៃដំណើរការនីតិវិធីរឿងក្ដី"។ វិធាន ២៣(១)(ក) នៃវិធានផ្ទៃក្នុងចែងថា ដើមបណ្ដឹងរដ្ឋប្បវេណី "ចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ប្រឆាំងនឹងអ្នកដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ដោយគាំទ្រដល់ការចោទប្រកាន់"។ វិធាន ១២*ស្ទួនពីរ*(១) ចែងថា សហមេធាវីនាំមុខ "ត្រូវធានាឲ្យមានប្រសិទ្ធិភាពអំពីការរៀបចំការតំណាងរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ចាប់ពីដំណាក់កាលជំនុំជម្រះឡើងទៅ ដែលធ្វើឲ្យមានតុល្យភាពនូវសិទ្ធិរបស់ភាគីទាំងអស់ និងតម្រូវការឲ្យការជំនុំជម្រះប្រព្រឹត្តទៅបានឆាប់រហ័ស ក្នុងបរិបទពិសេសរបស់ អ.វ.ត.ក"។

---

[២៣] សារណាតបរបស់ ខៀវ សំផន កថាខណ្ឌ ៧៦-៧៧។

[២៤] សារណាតបរបស់ ខៀវ សំផន កថាខណ្ឌ ៧៩។

[២៥] សារណាតបរបស់ ខៀវ សំផន កថាខណ្ឌ ៤៥ (យស់ ផល), ៤៦ (ស៊ូ សុធារី), ៥៦-៥៩ (អែម អឿន), ៨០ (មុំ វុន)។

[២៦] ឯកសារ **F10/2** សេចក្ដីសម្រេចលើសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងបណ្ដឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៤ កថាខណ្ឌ ២៣ ("សេចក្ដីសម្រេចលើឋានៈរបស់ដើមបណ្ដឹងរដ្ឋប្បវេណី")។

៥. នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនទៅលើឋានៈរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង ០០២/០១ និងសាលដីកាក្នុងសំណុំរឿង ០០២/៩១ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិឆ្លើយតបទៅនឹងសារណារបស់មេធាវីការពារក្តី រួមទាំងនៅក្នុងដំណាក់កាលប្តឹងសាទុក្ខនៅក្នុងកិច្ចដំណើរការនីតិវិធីផងដែរ[២៧] ដោយកំណត់ថា សារណាទាំងនោះប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ហើយពុំមែនជាបញ្ហាដដែលៗដែលសហព្រះរាជអាជ្ញាបានលើកឡើងរួចហើយនោះទេ[២៨]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលបានកម្រិតដែនកំណត់នៃសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញានៅក្នុងសំណុំរឿង ០០២/០១។ ជាពិសេស សំណើរបស់សហមេធាវីនាំមុខសុំបញ្ជាក់គោលជំហររបស់ខ្លួនចំពោះសារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ត្រូវបានជំទាស់ដោយផ្អែកលើមូលដ្ឋានថា សេចក្តីសង្ខេបទាំងនេះមិនអាច "ត្រូវបានគិតថាអនុលោមតាម ឬយកចេញមកពីវិធាន ២៣(១)(ក) នៃវិធានផ្ទៃក្នុងនោះឡើយ"[២៩]។

៦. អង្គជំនុំជម្រះតុលាការកំពូលបានផ្តល់សំអាងហេតុថា សិទ្ធិក្នុងការឆ្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី៖

> ដរាបណាទឡ្ហីករណ៍នៅក្នុងសារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី ប៉ះពាល់ដល់ផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី សិទ្ធិខ្លួនក្នុងការជំទាស់ទៅនឹងបណ្តឹងសាទុក្ខនេះ កើតចេញយ៉ាងសមហេតុផលពីបុព្វសិទ្ធិដែលបានផ្តល់ឲ្យដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងដំណាក់កាលស៊ើបអង្កេត ដំណាក់កាលជំនុំជម្រះ និងដំណាក់កាលបណ្តឹងសាទុក្ខ។ ជាពិសេស អង្គជំនុំជម្រះតុលាការកំពូលកត់

---

[២៧] ឯកសារ **F10/2** សេចក្តីសម្រេចលើឋានៈរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ១៤ និង ១៧។ ទោះបីសេចក្តីសម្រេចលើឋានៈរបស់ដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងនូវសិទ្ធិឆ្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីក៏ដោយ តែគោលការណ៍ស្នូលដែលមាននៅក្នុងសេចក្តីសម្រេចនោះអនុវត្តស្មើគ្នាចំពោះចម្លើយតបផ្សេងទៀត ហើយអង្គជំនុំជម្រះតុលាការកំពូលបានយកមកអនុវត្តទាក់ទិននឹងចម្លើយតបផ្សេងទៀតដែរ៖ *សូមមើល* ឯកសារ **F36** សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៨១។

[២៨] ឯកសារ **F10/2** សេចក្តីសម្រេចលើឋានៈរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ១៧។

[២៩] ឯកសារ **F10/2** សេចក្តីសម្រេចលើឋានៈរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ២៣។

សម្គាល់ថា "ភាគី" មានសិទ្ធិធ្វើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ នៅចំពោះមុខអង្គជំនុំជម្រះដែលមានសមត្ថកិច្ច រហូតដល់ពេលដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល ដូចមានចែងយ៉ាងលម្អិតនៅក្នុងសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ។ ការអនុញ្ញាតឱ្យដាក់បណ្តឹង និងសារណាជាលាយលក្ខណ៍អក្សរ រួមបញ្ចូលយ៉ាងសមហេតុផលនូវសិទ្ធិដាក់សារណាតប និងការឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានរបស់ភាគីមួយទៀត ដែលស្របទៅតាមក្របខណ្ឌនៃកិច្ចដំណើរការនីតិវិធីចំពោះមុខ[៣០]។

## III. សារណា

៧. ទោះបីមានការទទួលស្គាល់ថា សារណាទាំងនេះពុំស្ថិតនៅក្នុងក្របខណ្ឌជាក់លាក់នៃការធ្វើអំណះអំណាងដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង និងសេចក្តីណែនាំអនុវត្តក៏ដោយ ក៏សហមេធាវីនាំមុខសូមលើកឡើងថា សារណាទាំងនេះមានភាពចាំបាច់ ដោយពិចារណាទៅលើសារៈសំខាន់ជាចម្បងនៃភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំពោះសារណាតបរបស់ ខៀវ សំផន និងស្នើសុំដោយគោរពដល់អង្គជំនុំជម្រះមេត្តាពិចារណាចំពោះសារណាទាំងនោះ ដើម្បីរក្សាតុល្យភាពនៃសិទ្ធិក្នុងចំណោមភាគីនានា[៣១]។

៨. សហមេធាវីនាំមុខយល់ឃើញថាជាការចាំបាច់ដែលត្រូវលើកឡើងនូវសារណាមួយចំនួនដែល ខៀវ សំផន បានលើកឡើង។ សារណាក្នុងនាមដើមបណ្តឹងរដ្ឋប្បវេណីអាចទទួលយកបាន អនុលោមតាមគោលការណ៍នានាដែលបានបង្កើតឡើង ដោយសារ៖

(ក) សារណាទាំងនេះលើកឡើង (និងត្រូវបានកម្រិតត្រឹមតែ) បញ្ហានានាដែលប៉ះពាល់ដោយផ្ទាល់ទៅលើសិទ្ធិ និងផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី។ ជាពិសេស ការអះអាងនានាដែលបានធ្វើឡើងនៅក្នុងសារណាតបរបស់ ខៀវ សំផន ទាក់ទិននឹងភាពជឿជាក់បាន និងភាពទុកចិត្តបាននៃភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី និង ភាពពាក់ព័ន្ធនៃភស្តុតាងទាំងនោះទៅនឹងបញ្ហាមួយចំនួន។ ដើម

[៣០] ឯកសារ **F10/2** សេចក្តីសម្រេចលើឋានៈរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ១៤។

[៣១] ឯកសារ **F10/2** សេចក្តីសម្រេចលើឋានៈរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ១៤, ១៧។

បណ្តឹងរដ្ឋប្បវេណីដែលទទួលរងប៉ះពាល់ មានផលប្រយោជន៍ក្នុងការបញ្ចេញយោបល់ដើម្បីការពារខ្លួន ទាក់ទិននឹងគុណភាពនៃភស្តុតាងរបស់ខ្លួន និងដាក់សារណាអំពីបញ្ហានៃភាពពាក់ព័ន្ធរបស់ភស្តុតាងទាំងនោះ។

(ខ) សារណាទាំងនេះមិនគ្របដណ្តប់ទៅលើបញ្ហានានាដែលបានលើកឡើងនៅក្នុងសារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា និងដែលចេញមកពីវិធាន ២៣ (១)(ក) នៃវិធានផ្ទៃក្នុង ជាសារណាដែលគាំទ្រដល់ការចោទប្រកាន់នោះឡើយ។

៩. ដោយពិចារណាទៅលើសារណាស្តីពីបញ្ហាដែលត្រូវបានកម្រិតទាំងនោះ ស្ថិតក្នុងការទទួលស្គាល់របស់អង្គជំនុំជម្រះតុលាការកំពូលថា ភាគីនីមួយៗនៅក្នុងកិច្ចដំណើរការនីតិវិធីមាន "មុខងារ និងការទទួលខុសត្រូវជាក់លាក់របស់ខ្លួននៅក្នុងកិច្ចដំណើរការនីតិវិធី"[៣២]។ សហមេធាវីនាំមុខជាបុគ្គលដែលមានការទទួលខុសត្រូវក្នុងការលើកឡើងអំពីផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណីជូនអង្គជំនុំជម្រះ[៣៣]។ នៅពេលដែលភាគីម្ខាងទៀតវាយប្រហារដោយផ្ទាល់ទៅលើភាពជឿជាក់បានរបស់ដើមបណ្តឹងរដ្ឋប្បវេណី សហមេធាវីនាំមុខជាបុគ្គលស័ក្តិសមបំផុតក្នុងការលើកឡើងនូវបញ្ហាទាំងនេះជូនអង្គជំនុំជម្រះ។

១០. សហមេធាវីនាំមុខទទួលស្គាល់ថា ពេលវេលានៃការដាក់សារណាទាំងនេះខុសប្រក្រតី ដោយសារពួកគេលើកឡើងនូវការឆ្លើយតបទៅនឹងសារណារបស់ភាគីម្ខាងទៀត។ ទោះជាយ៉ាងណាក្តី គួរកត់សម្គាល់ថា ខៀវ សំផន ក៏បានប្រើវិធីស្រដៀងគ្នាដែរនាពេលថ្មីៗនេះ នៅពេលគាត់បានធ្វើអន្តរាគមន៍សុំដាក់សារណាតប ទៅនឹងការឆ្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើបន្ទាន់របស់ក្រុមមេធាវីការពារក្តី នួន ជា បន្ទាប់ពីគាត់បានទទួលមរណភាព[៣៤]។ សារណាទាំងនេះត្រូវបានដាក់បន្ទាប់ពីមានចម្លើយតបរបស់សហព្រះរាជ

---

[៣២] ឯកសារ **F10/2** សេចក្តីសម្រេចលើឋានៈរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ១១។

[៣៣] វិធាន ១២*ស្ទួនពីរ*(១), (៥) នៃវិធានផ្ទៃក្នុង។

[៣៤] *សូមមើល* ឯកសារ **F46/2/4/1** ការឆ្លើយតបរបស់លោក ខៀវ សំផន ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងសច្ចធារណ៍និរទោស នៅដំណាក់កាលបណ្តឹងសាទុក្ខ (ឯកសារ F46/2/4) ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៩ កថាខណ្ឌ ៥។

អាជ្ញា ទោះបី ខៀវ សំផន មិនបានឆ្លើយតបទៅនឹងសារណាដើមរបស់ នួន ជា ក៏ដោយ។ នាពេលនេះ សហមេធាវីនាំមុខស្នើសុំប្រើប្រាស់វិធីដូចគ្នានេះដែរ។

១១. មានពីរចំណុចខុសគ្នា ត្រូវបានលើកឡើងនៅក្នុងចម្លើយតបរបស់មេធាវីការពារក្តីលោក ខៀវ សំផន ពាក់ព័ន្ធទៅនឹងការប្រើប្រាស់ភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី អែម អឿន។

១២. សហមេធាវីនាំមុខ សូមបដិសេធការវាយតំលៃរបស់ ខៀវ សំផន ថាភស្តុតាងរបស់ អែម អឿន ខ្វះខាតភាពគួរឱ្យជឿជាក់ និងភាពគួរឱ្យជឿទុកចិត្តបាន[៣៥]។ ជាក់ស្តែង អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០១ ដែលបានស្តាប់សក្ខីកម្មរបស់ អែម អឿន ដោយផ្ទាល់នៅក្នុងសាលសវនាការ បានធ្វើការវាយតម្លៃថា មានភាពជឿជាក់បាន ហើយបានផ្អែកលើភស្តុតាងរបស់ អែម អឿន ជាច្រើនកន្លែងនៅក្នុងសាលក្រម របស់ខ្លួន[៣៦]។ នៅដំណាក់កាលបណ្តឹងសាទុក្ខនៃសំណុំរឿង ០០២/០១ ខៀវ សំផន ព្យាយាមជំទាស់ទៅនឹង ភាពជឿទុកចិត្តបាននៃភស្តុតាងរបស់ អែម អឿន ប៉ុន្តែ អង្គជំនុំជម្រះតុលាការកំពូល បានបដិសេធចោលលើអំណះអំណាងនេះ។ អង្គជំនុំជម្រះ តុលាការកំពូលបានទទួលស្គាល់ថា អែម អឿន មានការលំបាកក្នុងការរំលឹកឡើងវិញ អំពី*ពេលវេលា*ដែលព្រឹត្តការណ៍នានាបានកើតឡើង ប៉ុន្តែអង្គជំនុំជម្រះតុលាការកំពូល មិនបានចាត់ទុកថាការលំបាកក្នុងការរំលឹកឡើងវិញនោះ ធ្វើឱ្យអន្តរាយផលប្រយោជន៍ នៃភស្តុតាងរបស់គាត់នោះឡើយ នៅពេលដែលភស្តុតាងរបស់គាត់ត្រូវបានប្រើប្រាស់ ដោយអង្គជំនុំជម្រះសាលាដំបូង[៣៧]។ សម្រាប់មូលហេតុដូចគ្នាដែរ ការអះអាងរបស់ ខៀវ

---

[៣៥] ឯកសារ **F50/1** សារណាតបរបស់ ខៀវ សំផន កថាខណ្ឌ ៥៨។

[៣៦] ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ ទំព័រ១៦៧ កំណត់សំគាល់ ៩៨១; ទំព័រ១៧០ កំណត់សំគាល់ ៩៩៧; ទំព័រ១៩៥ កំណត់សំគាល់ ១១៤៣; ទំព័រ២៥៨ កំណត់សំគាល់ ១៤៤៦; ទំព័រ២៨០ កំណត់សំគាល់ ១៥៤៨; ទំព័រ៤៤៧ កំណត់សំគាល់ ២៤៣៦; ទំព័រ៤៧៦ កំណត់សំគាល់ ២៥៨០។

[៣៧] អែម អឿន បានទទួលស្គាល់ថាមានបញ្ហាលំបាកក្នុងការរំលឹកឡើងវិញទៅតាមលំដាប់លំដោយ នូវព្រឹត្តិការណ៍ ដែលបានកើតឡើងអស់រយៈពេល ៤០ ឆ្នាំកន្លងទៅ និងដោយមានការប៉ះទង្គិចផ្លូវចិត្ត បានធ្វើឱ្យប៉ះពាល់ដល់ ការចងចាំរបស់គាត់។ ទោះជាយ៉ាងណាក្តី ខៀវ សំផន ពុំបានផ្តល់សេចក្តីយោងទៅលើសាលក្រមរបស់

សំផន ដែលលើកឡើងពេលនេះថា ភស្តុតាងរបស់ អែម អឿន មិនអាចជឿជាក់ ឬមិនអាចជឿទុកចិត្តបាននោះ គឺត្រូវតែបដិសេធចោល។ ខ្លឹមសារនៃសក្ខីកម្ម របស់គាត់ គឺមានភាពជឿជាក់បាន ចំពោះករណីដែលប្រើប្រាស់ដោយសហព្រះរាជអាជ្ញា។

១៣. ទីពីរ សហមេធាវីនាំមុខ កត់សំគាល់ សំអាងហេតុរបស់ ខៀវ សំផន ទាក់ទងទៅនឹង ការកំណត់វិសាលភាពនៃការសាកសួរ អែម អឿន នៅក្នុងសំណុំរឿង ០០២/០១[៣៨]។ ការបកស្រាយដ៏ទូលំទូលាយនៃសំអាងហេតុនេះ (មិនជាក់លាក់ចំពោះ អែម អឿន) ក៏ជាមូលដ្ឋាននៃបណ្តឹងសាទុក្ខនៅក្នុងសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ផងដែរ។ ដើម្បីប្រសិទ្ធភាព និងដើម្បីជៀសវាងនូវភាពច្រំដែល សហមេធាវីនាំមុខ សូមមិនធ្វើការឆ្លើយតបចំពោះសំអាងហេតុនេះ នៅពេលនេះទេពាក់ព័ន្ធទៅនឹង អែម អឿន ប៉ុន្តែ អាចឆ្លើយតបនៅក្នុងបរិបទនៃបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ដោយអាស្រ័យ លើសារណានានាពីសហព្រះរាជអាជ្ញា និងតម្រូវការជៀសវាងការច្រំដែល[៣៩]។

## IV. សំណើ

**អាស្រ័យហេតុនេះ** ដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំដោយគោរពដល់អង្គជំនុំជម្រះតុលាការកំពូល មេត្តា៖

(១) **ពិចារណា**ដល់សារណាទាំងនេះនៅក្នុងការសម្រេចរបស់អង្គជំនុំជម្រះ ទៅលើ បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា។

សូមលោក-លោកស្រីចៅក្រមមេត្តាទទួលយកសារណានេះដោយគោរព

---

អង្គជំនុំជម្រះសាលាដំបូង ឬចំណុចប៉ះពាល់ណាមួយដែលបង្ហាញឱ្យឃើញថា ការដែលអង្គជំនុំជម្រះសាលាដំបូង ពុំបានពិចារណា បានធ្វើឱ្យប៉ះពាល់ដល់ការសម្រេចនៅក្នុងសាលក្រម: ឯកសារ **F36** សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៣៤៧ ។

[៣៨] ឯកសារ **F50/1** សារណាតបរបស់ ខៀវ សំផន កថាខណ្ឌ ៥៧។

[៣៩] ដូចទៅតាមលក្ខខណ្ឌដែលបានកំណត់នៅក្នុង ឯកសារ **F10/2** សេចក្តីសម្រេចលើឋានៈរបស់ដើមបណ្តឹង រដ្ឋប្បវេណី កថាខណ្ឌ ១៧។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី០៧ ខែតុលា ឆ្នាំ ២០១៩ | ពេជ្ជ អង្គ<br>សហមេធាវីនាំមុខ | ភ្នំពេញ | |
| | Megan HIRST<br>សហមេធាវីនាំមុខ | London | |